ទីស្ដីការក្រសួងយុត្តិធម៌
លេខ ០៥ សរច-៩៤

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## សារាចរ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ស្ទូមជម្រាបមក**

លោក ប្រធានតុលាការគ្រប់ខេត្ត ក្រុង

លោកព្រះរាជអជ្ញាអមតុលាការគ្រប់ខេត្ត ក្រុង

**សូមជ្រាប។**

**កម្មវត្ថុ:** សេចក្ដីណែនាំអំពីការចោទប្រកាន់ជនល្មើសពីបទសមគំនិ និងអំណាចនៃការចេញដីកាចាប់ខ្លួន ។

ខ្ញុំសូមជម្រាបលោកថា ក្រោយពីបានពិនិត្យនូវរបាយការណ៍ និងស្ថិតិប្រចាំខែរបស់តុលាការនិងអយ្យការគ្រប់ខេត្ត-ក្រុង ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញមានចំណុច ២សំខាន់ ដែលត្រូវអស់លោកយកចិត្តទុកដាក់អនុវត្តអោយបានត្រឹមត្រូវតាមច្បាប់ ៖

**១-ការចោទប្រកាន់ជនសមគំនិត**

តាមគោលការណ៍ ក្នុងបទល្មើសមួយអាចធ្វើការចោទប្រកាន់ជនសមគំនិតបាន លុះត្រាតែមានការចោទប្រកាន់ជនល្មើសដៃដល់ជាមុន ទោះបីជាក្នុងករណីជនល្មើសដៃដល់នោះត្រូវស្លាប់ រត់គេចខ្លួនបាត់ គ្មានសាវតារជាតិ ជាអនីតិជន ជាជនវិកលចរិត ដោយច្បាប់ទទួលស្គាល់បុព្វសិទ្ធិ ជាធម្មជាតិ ឬដោយច្បាប់ក៏ដោយ ក៏ត្រូវមានចុះឈ្មោះសម្គាល់ជនល្មើសដៃដល់នេះមុនឈ្មោះជនល្មើសសមគំនិត ដែលត្រូវទទួលខុសត្រូវជាបទអាជ្ញាជាដរាប ពីព្រោះក្នុងគ្រប់បទអាជ្ញា ពុំត្រូវចោទប្រកាន់ជនសមគំនិតដោយពុំបានចោទប្រកាន់ជនល្មើសដៃដល់ឡើយ ។

**២-អំណាចនៃការចេញដីកាចាប់ខ្លួន**

សំណុំរឿងព្រហ្មទណ្ឌមួយក្នុងចំណាត់ការដែលអយ្យការកំពុងធ្វើការស៊ើបអង្កេតបឋម តាមនីតិវិធីនៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី១០-០៩-៩២ នឹងតាមច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ២១ ចុះថ្ងៃទី០៨-០៣-៩៣ ព្រះរាជអាជ្ញាពុំមានសិទ្ធិចេញដីកាចាប់ខ្លួនមនុស្សត្រូវចោទទេ លើកលែងតែករណីបទល្មើសជាក់ស្ដែង លោកធ្វើការពិនិត្យបទល្មើសនៅនឹងទីកន្លែងប្រព្រឹត្តបទល្មើស ហើយជនល្មើសត្រូវបានឃាត់ខ្លួននោះទើបលោកអាចចោទប្រកាន់បញ្ជូនជនល្មើសនេះទៅជំនុំជម្រះផ្ទាល់តាមនិតិវិធី ដើម្បីសុំឱ្យចៅក្រមជំនុំជម្រះកាត់ទោសតាមច្បាប់ ។ ក្នុងករណីនេះ បើចៅក្រមជំនុំជម្រះមិនអាចដាក់ជំនុំជម្រះបានភ្លាមៗទេនោះ ចៅក្រមជំនុំជម្រះត្រូវសម្រេចអំពីការឃុំខ្លួនឬអនុញ្ញាតអោយនៅក្រៅឃុំជាបណ្ដោះអាសន្ន ។ ប្រសិនបើទោសដែលមានចែងក្នុងបទល្មើសដែលជននេះបានប្រព្រឹត្តមានកំណត់ទណ្ឌកម្មដាក់ពន្ធនាគារលើសពី ១ ឆ្នាំ លោកព្រះរាជអាជ្ញាត្រូវតែធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងទៅចៅក្រមស៊ើបអង្កេត ដើម្បីចៅក្រមស៊ើបអង្កេតពិនិត្យសម្រេចអំពីការឃុំខ្លួន ឬអនុញ្ញាតអោយទៅក្រៅឃុំបណ្ដោះរសន្ន ។

សូមលោកពិនិត្យអំពីចំណាត់ការរបស់អស់លោកឡើងវិញ ហើយអនុវត្តតាមសេចក្ដីណែនាំខាងលើនេះឲ្យបានត្រឹមត្រូវ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៩៤

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**អ៊ិត រ៉ឹធុន**

ចម្លងជូន

-តុលាការកំពូល

-មហាអយ្យការអមតុលាការកំពូល

-សាលាឧទ្ធរណ៍

-មហាអយ្យការអមសាលាឧទ្ធរណ៍

-ប្រធានតុលាការយោធា

-ព្រះរាជអាជ្ញាអមតុលាការយោធា

-ដើម្បីជូនជ្រាប និងអនុវត្ត